# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ</u>

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០២០ រវាងលោក **ប៉ុល សុខេង** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៨០២៥៧០៧១ ដែលមានតួនាទីជា **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **អលមិន ខូ អិលធីឌី** ដែលមានអាសយដ្ឋានស្ថិតនៅ **ផ្ទះលេខ១២៨អេឭ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** ធ្វើជាមួយនិង ៖

- **លោក ហ៊ៅ លីដា** កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ០២១១៦៥៥២៤
  ដែលមានតួនាទីជាប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ ។
- **លោក កែវ ម៉េងលី** កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ០៦២១១៥៦២៧
  ដែលមានតួនាទីជាជំនួយការ ការិយាល័យជួរមុខ និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ ។
- **លោកស្រី ផល ពៅសុជាតា** កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ០១០៥០៧៨៣១
  ដែលមានតួនាទីជា ជំនួយការប្រធានផ្នែកភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**១-<u>រយៈពេលនៃការព្យួរកិច្ចសន្យាការងារ ៖</u>**

ការព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ-១៩ ។

**២-<u>ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ ៖</u>**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

ភាគីនិយោជិត មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

**៣-<u>កាលបរិច្ឆេទចូលបម្រើការងារវិញ ៖</u>**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។ កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។
ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព។

រាជធានីភ្នំពេញថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០២០

**តំណាងភាគីនិយោជិត**

**លោក ហ៊ៅ លីដា** **លោក កែវ ម៉េងលី** **លោក ផល ពៅសុជាតា**

**តំណាងភានិយោជក**

**លោក ប៉ុល សុខេង**